# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :.........០១២/១៤..........ក.ប/ស.ណ.ន

# សារាចរណែនាំ

## ស្តីពី

## ការពង្រឹងការអនុវត្តវិធានការ បន្ថែមដើម្បីដោះស្រាយករណីពលករទេសន្តរប្រវេសន៍ខ្មែរ ដែលទើបវិលត្រឡប់ពីព្រះរាជាណាចក្រថៃឡង់ដ៍

យោងតាមស្មារតីនៃកិច្ចប្រជុំកាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤ របស់គណៈកម្មការសម្រាប់ដោះស្រាយករណីពលករទេសន្តរប្រវេសន៍ខ្មែរ ដែលទើបវិលត្រឡប់មកពីព្រះរាជាណាចក្រថៃឡង់ដ៍ និងលិខិតលេខ ៩០៣សជណ អវ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ និងលិខិតលេខ ៩៣៥ សជណ អវ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសូមធ្វើការណែនាំដល់អង្គភាពក្រោមឱវាទដូចតទៅ៖

១-អគ្គនាយកដ្ឋានការងារ ត្រូវ៖

១. បន្តសហការជាមួយភាគីថៃ ដើម្បីពង្រឹងការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាលើការប្រើប្រាស់កម្លាំងពលកម្មនៃប្រទេសទាំងពីរ និងកិច្ចព្រមព្រៀងនានាដែលបានឯកភាពគ្នាកន្លងមក។

២. សម្រួលការរៀបចំបែបបទជូនពលករដែលមានបំណង ទៅធ្វើការដោយស្របច្បាប់នៅប្រទេសថៃវិញដោយតម្រូវឱ្យពលករគ្រប់រូបត្រូវមានបែបបទដូចតទៅ៖

- កិច្ចសន្យាការងារជាមួយក្រុមហ៊ុន ដែលទទួលឱ្យធ្វើការ។ កិច្ចសន្យាការងារនេះអាចធ្វើតាមរយៈទីភ្នាក់ងារជ្រើសរើសពលករស្របច្បាប់ណាមួយ ដែលបានចុះបញ្ជិកាជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬអាចធ្វើផ្ទាល់រវាងពលករ និងក្រុមហ៊ុនដែលទទួលឱ្យធ្វើការងារតែម្តង។
- ប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស។
- លិខិតឆ្លងដែនដែលចេញដោយក្រសួងមហាផ្ទៃ។
- ទិដ្ឋាការការងារដែលចេញដោយកុងស៊ុល នៃស្ថានឯកអគ្គរាជទូតថៃ។

៣. បង្កើតឱ្យមានសេវាច្រកចេញចូលតែមួយនៅតាមគោលដៅ ដែលចាំបាច់ដើម្បីផ្តល់ និងឯកសារជូនដល់ពលករដែលចង់ទៅធ្វើការនៅប្រទេសថៃ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

៤. ត្រូវផ្សព្វផ្សាយបញ្ជីឈ្មោះទីភ្នាក់ងារជ្រើសរើសពលករស្របច្បាប់ ដែលចុះបញ្ជិកានៅក្រសួងដល់សាធារណជនជ្រាបឱ្យបានទូលំទូលាយ និងផ្តល់ឯកសារពាក់ព័ន្ធនឹងការចុះជ្រើសរើសពលកររបស់បណ្តាញភ្នាក់ងារ នៃទីភ្នាក់ងារជ្រើសរើសពលករដល់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្តដើម្បីចូលរួមសហការត្រួតពិនិត្យ និងតាមដាន។

៥. ត្រួតពិនិត្យឱ្យបានហ្មត់ចត់នូវការអនុវត្តកិច្ចសន្យារបស់ទីភ្នាក់ងារជ្រើសរើសពលករ និងចាត់វិធានការតឹងរឹងចំពោះទីភ្នាក់ងារជ្រើសរើសពលករទាំងឡាយណា ដែលជួលអាជ្ញាប័ណ្ណបន្ត ឬមិនបានសុំការអនុញ្ញាតខ្លឹមសារផ្សាយព័ត៌មាន ស្តីពីឱកាសការងារនៅបរទេសតាមបណ្តាញសារព័ត៌មានជាមុន ឬមិនបានអនុវត្តតាមបទប្បញ្ញត្តិ ច្បាប់ និងសេចក្តីណែនាំរបស់ក្រសួង។ ត្រូវបង្កើតឱ្យមានរបបប្រជុំត្រួតពិនិត្យ ប្រចាំត្រីមាស រវាងក្រសួង និងទីភ្នាក់ងារជ្រើសរើសពលករ។

៦. ខិតខំសហការជាមួយអង្គភាពនានាផ្តល់ព័ត៌មានឱកាសការងារ និងផ្តល់សេវារកការងារក្នុងស្រុកជូនពលករដែលទើបធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញឱ្យបានទូលំទូលាយតាមរយៈ៖

- មន្ត្រីតំណាងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលប្រចាំការនៅគ្រប់ការិយាល័យច្រកចេញចូលតែមួយ ក្នុងតំបន់សេដ្ឋកិច្ចពិសេសត្រូវធ្វើការប្រមូល និងណែនាំដល់គ្រប់គ្រឹះស្ថាន សហគ្រាស ស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេសឱ្យធ្វើការបញ្ជូនព័ត៌មានជ្រើសរើសកម្លាំងពលកម្មមកទីភ្នាក់ងារជាតិមុខរបរ និងការងារ។
- ក្រុមអធិការកិច្ចការងារតែមួយ ត្រូវប្រមូលព័ត៌មានស្តីពីការជ្រើសរើសកម្លាំងពលកម្មពីគ្រឹះស្ថាន សហគ្រាស ដើម្បីផ្ញើជូនទីភ្នាក់ងារជាតិមុខរបរ និងការងារ ធ្វើការផ្សព្វផ្សាយជូនពលករមាតុភូមិនិវត្តន៍ និងប្រជាពលរដ្ឋដែលកំពុងស្វែងរកការងារធ្វើ។ ត្រូវធ្វើការណែនាំដល់គ្រប់គ្រឹះស្ថាន សហគ្រាស ឱ្យបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការផ្ញើព័ត៌មាន ស្តីពីការជ្រើសរើសកម្លាំងពលកម្មជូនទីភ្នាក់ងារជាតិមុខរបរ និងការងារ។

**២-អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវ៖**

១. ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី និងមធ្យមដល់ពលករដែលមានបំណងចង់រៀនវិជ្ជាជីវៈសម្រាប់ស្វែងរកការងារធ្វើក្នុងស្រុក។

២. ខិតខំរៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញ ដែលចាំបាច់សម្រាប់ឱ្យពលករអាចយកទៅបម្រើការងារក្នុងស្រុកតាមតម្រូវការទីផ្សារការងារ។

៣. ផ្តល់ព័ត៌មានស្តីពីវគ្គបណ្តុះបណ្តាលជំនាញគ្រប់ប្រភេទ ដើម្បីធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយជូនដល់ពលករមាតុភូមិនិវត្តន៍ពីប្រទេសថៃ និងប្រជាពលរដ្ឋដែលមានសេចក្តីត្រូវការបណ្តុះបណ្តាលលើកកម្ពស់ជំនាញ។

៤. ប្រមូលទិន្នន័យអំពីការចុះឈ្មោះចូលរៀនរបស់ពលករតាមមជ្ឈមណ្ឌល។

៥. ក្នុងករណីចាំបាច់ត្រូវរៀបចំស្នើមូលនិធិពិសេស របស់សម្ដេចតេជោនាយករដ្ឋមន្ត្រី សម្រាប់ជួយទ្រទ្រង់ដល់ពលករ ដែលមានការខ្វះខាតជីវភាពក្នុងការសិក្សាជំនាញបច្ចេកទេសវិជ្ជាជីវៈ។
៦. ចាត់តាំងជនបង្គោល (Focal Point) ដែលត្រូវធ្វើការទំនាក់ទំនងជាមួយទីភ្នាក់ងារជាតិមុខរបរ និងការងារ ដើម្បីធ្វើការផ្លាស់ប្តូរ និងបញ្ជូនព័ត៌មានឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាពខ្ពស់។

**៣-ទីភ្នាក់ងារជាតិមុខរបរ និងការងារ ត្រូវ៖**

១. រៀបចំចុះឈ្មោះរកការងារធ្វើ និងបង្កើនការផ្សព្វផ្សាយអំពីព័ត៌មានទីផ្សារការងារ និងឱកាសការងារក្នុងស្រុក។
២. ប្រមូលព័ត៌មាន និងធ្វើបច្ចុប្បន្នកម្មអំពីតម្រូវការជ្រើសរើសកម្លាំងពលកម្ម គ្រប់ប្រភេទទូទាំងប្រទេស ដើម្បីធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងឆាប់រហ័ស តាមរយៈគេហទំព័រមជ្ឈមណ្ឌលការងារ មន្ទីរការងាររាជធានី-ខេត្ត អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ព្រមទាំងសារព័ត៌មាន វិទ្យុ ទូរទស្សន៍ និងមធ្យោបាយផ្សេងៗទៀត ជូនពលករមាតុភូមិនិវត្តន៍ពីប្រទេសថៃ និងប្រជាពលរដ្ឋដែលកំពុងស្វែងរកការងារធ្វើ។
៣. គ្រប់គ្រង និងសហការប្រមូលចងក្រងទិន្នន័យអំពីពលករមាតុភូមិនិវត្តន៍ពីប្រទេសថៃ ដើម្បីធ្វើការបូកសរុប និងរាយការណ៍ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងផ្តល់ជាមុខចូលដល់អង្គភាពពាក់ព័ន្ធ ក្នុងការចាត់វិធានការអន្តរាគមន៍ជួយស្វែងរកការងារធ្វើ និងបណ្តុះបណ្តាលជំនាញទាន់ពេលវេលាជូនពលករដែលបានធ្វើមាតុភូមិនិវត្តន៍។
៤. សហការជាមួយមន្ទីរការងាររាជធានី-ខេត្ត អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ព្រមទាំងក្រុមហ៊ុន គ្រឹះស្ថាន សហគ្រាសនានាដើម្បីរៀបចំវេទិកាការងារនៅតាមមូលដ្ឋានគោលដៅ សំដៅផ្សព្វផ្សាយព័ត៌មានអំពីឱកាសការងារ ការបណ្តុះបណ្តាលជំនាញ និងជួយស្វែងរកការងារធ្វើក្នុងស្រុកជូនដល់ពលករមាតុភូមិនិវត្តន៍ពីប្រទេសថៃ និងប្រជាពលរដ្ឋដែលកំពុងស្វែងរកការងារធ្វើ។
៥. ទំនាក់ទំនងជាមួយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្រោមឱវាទក្រសួងដើម្បីសុំឈ្មោះជនបង្គោល (Focal Point) ដើម្បីធ្វើការទំនាក់ទំនងផ្លាស់ប្តូរ និងបញ្ជូនព័ត៌មានទៅវិញទៅមកបានឆាប់រហ័ស និងមានប្រសិទ្ធភាព។
៦. រៀបចំជាតារាងតាមដានត្រួតពិនិត្យ (Check List) សម្រាប់ឱ្យក្រុមអធិការកិច្ចការងារតែមួយ ជួយប្រមូលទិន្នន័យ និងព័ត៌មានដែលចង់បាន។

**៤-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត ត្រូវ៖**

១. ធ្វើការប្រមូលព័ត៌មាន ស្តីពីការជ្រើសរើសកម្លាំងពលកម្មពីគ្រឹះស្ថាន សហគ្រាស គ្រប់ប្រភេទដើម្បីធ្វើជូនទីភ្នាក់ងារជាតិមុខរបរ និងការងារ និងធ្វើការផ្សព្វផ្សាយឱ្យបានទូលំ

ទូលាយដល់ពលករមាតុភូមិនិវត្តន៍ពីប្រទេសថៃ និងប្រជាពលរដ្ឋដែលកំពុងស្វែងរកការងារធ្វើនៅក្នុងរាជធានី-ខេត្ត ស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។

២. សហការជាមួយអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ធ្វើការប្រមូល ចងក្រង និងគ្រប់គ្រងទិន្នន័យ ស្តីពីពលករមាតុភូមិនិវត្តន៍ពីប្រទេសថៃ ឱ្យបានច្បាស់លាស់ ដើម្បីផ្ញើជូនទីភ្នាក់ងារជាតិមុខរបរ និងការងារព្រមទាំងចាត់វិធានការអន្តរាគមន៍ឱ្យបានទាន់ពេលវេលា។

៣. ត្រូវសហការជាមួយទីភ្នាក់ងារជាតិមុខរបរ និងការងារ និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់រៀបចំវេទិកាការងារនៅតាមមូលដ្ឋាន ដែលមានពលករមាតុភូមិនិវត្តន៍ពីប្រទេសថៃ និងប្រជាពលរដ្ឋកំពុងស្វែងរកការងារធ្វើច្រើន សំដៅផ្សព្វផ្សាយព័ត៌មានអំពីឱកាសការងារក្នុងស្រុក និងផ្តល់សេវាជួយស្វែងរកការងារធ្វើឱ្យបានឆាប់រហ័ស និងងាយស្រួល ព្រមទាំងជួយគាំទ្រដល់គ្រឹះស្ថាន សហគ្រាសនានា ដែលកំពុងត្រូវការជ្រើសរើសកម្លាំងពលកម្ម។

៤. ចាត់តាំងជនបង្គោល (Focal Point) ដែលត្រូវធ្វើការទំនាក់ទំនងជាមួយទីភ្នាក់ងារជាតិមុខរបរ និងការងារ ដើម្បីធ្វើការផ្លាស់ប្តូរ និងបញ្ជូនព័ត៌មានឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាពខ្ពស់។

៥. ជួយសម្រួលពលករក្នុងការរកការងារធ្វើតាមរោងចក្រសហគ្រាស ដែលមានទីតាំងនៅរាជធានី-ខេត្ត ហើយកំពុងត្រូវការជ្រើសរើសពលករ។

៦. ត្រូវរៀបចំផ្តល់ព័ត៌មានដល់អាជ្ញាធរមានសមត្ថកិច្ចនូវបញ្ជីឈ្មោះទីភ្នាក់ងារជ្រើសរើសពលករស្របច្បាប់ដែលបានចុះបញ្ជិកា ជាមួយក្រសួង និងត្រូវត្រួតពិនិត្យ តាមដានឱ្យបានហ្មត់ចត់នូវសកម្មភាពរបស់ភ្នាក់ងារជ្រើសរើសពលករ នៅក្នុងមូលដ្ឋានរបស់ខ្លួនដើម្បីទប់ស្កាត់ការជួលអាជ្ញាប័ណ្ណបន្តគ្នា និងធ្វើការជ្រើសរើសដោយខុសច្បាប់។

ទទួលបានសារាចរណែនាំនេះ ឯកឧត្តម លោក លោកស្រី មន្ត្រីរាជការដែលទទួលបន្ទុកអនុវត្តភារកិច្ចខាងលើត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០១៤

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន៖**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
"ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ